**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**អគ្គនាយកដ្ឋាន**
**សហប្រតិបត្តិការអន្តរជាតិ**

សេចក្តីប្រកាសព័ត៌មាន

## «កម្ពុជាត្រៀមខ្លួនរួចជាស្រេចក្នុងកិច្ចសហការជាមួយប្រទេសដទៃទៀតដើម្បីដោះស្រាយការគំរាមកំហែងនៃគ្រឿងញៀនសំយោគ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ»

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ - **ឯកឧត្តម អ៊ុច បូរិទ្ធ** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួម "កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីដើម្បីដោះស្រាយការគំរាមកំហែងនៃគ្រឿងញៀនសំយោគ តាមប្រព័ន្ធនិម្មិត" ដែលដឹកនាំដោយ**ឯកឧត្តម** Antony J. Blinken រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក នាថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣។ វត្តមាននៅក្នុងកិច្ចប្រជុំនេះរួមមានរដ្ឋមន្ត្រីការបរទេស/រដ្ឋមន្ត្រី មកពីជាង ៥០ប្រទេស ព្រមទាំងប្រធាននៃអង្គការអន្តរជាតិនានា។

ក្នុងកំឡុងពេលនៃកិច្ចប្រជុំ រដ្ឋមន្ត្រីទាំងអស់បានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងអំពីគ្រោះថ្នាក់ទៅលើសុខភាពសាធារណៈ និងសង្គម ដែលបណ្តាលមកការប្រើប្រាស់គ្រឿងញៀនសំយោគ ដែលមិនស្របតាមក្បួនវេជ្ជសាស្ត្រ។ រដ្ឋមន្ត្រីទាំងអស់បានបញ្ជាក់នូវការប្តេជ្ញាចិត្តក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ និងខិតខំរួមគ្នាកំណត់នូវអាទិភាពសំខាន់ៗ។ រដ្ឋមន្ត្រីទាំងអស់បានប្តេជ្ញាចិត្តផងដែរក្នុងការបង្កើតឱ្យបាននូវដំណោះស្រាយឆ្ពោះទៅមុខ ជំរុញឱ្យកាន់តែប្រសើរនូវគំនិតផ្តួចផ្តើមថ្នាក់ជាតិ និងអន្តរជាតិ និងធានាថា គ្រប់ទិដ្ឋភាពនៃការកាត់បន្ថយតម្រូវការ និងការផ្គត់ផ្គង់ ក៏ដូចជាកិច្ចសហប្រតិបត្តិការអន្តរជាតិ គួរស្របតាមគោលបំណង និងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ច្បាប់អន្តរជាតិ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។


អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ថ្លែងនៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តម **អ៊ុច បូររិទ្ធ** បានគូសបញ្ជាក់ពីសារៈសំខាន់ក្នុងការអនុវត្ត សកម្មភាពជាក់ស្តែង និងបង្កើតដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត ដើម្បីបង្ក្រាបការផលិត និងការជួញដូរគ្រឿងញៀនសំយោគដោយខុសច្បាប់ ក្នុងពេលនោះដែរត្រូវកាត់បន្ថយផលប៉ះពាល់ គ្រោះថ្នាក់ទៅលើសុខភាពសាធារណៈ។ **ឯកឧត្តម**បានលើកឡើងអំពីការខិតខំប្រឹងប្រែង និង វិធានការនានារបស់កម្ពុជាក្នុងការដោះស្រាយបញ្ហាគ្រឿងញៀន រួមមាន ការអនុវត្តច្បាប់ គោល នយោបាយ និងផែនការសកម្មភាពសំខាន់ៗ។ កម្ពុជា  បានធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹង អំពីគ្រឿងញៀនយ៉ាងទូលំទូលាយដល់សាធារណជនទូទៅ និងក្រុមគោលដៅ។ កម្ពុជាបានពង្រឹង វិធានការគ្រប់គ្រង និងត្រួតពិនិត្យលើការនាំចូល ការចែកចាយ និងការប្រើប្រាស់សារធាតុគីមីផ្សំ យ៉ាងហ្មត់ចត់ ដើម្បីបង្ការការផលិតគ្រឿងញៀនខុសច្បាប់ដោយប្រើសារធាតុគីមីផ្សំដែលយកមកពី ការធ្វើពាណិជ្ជកម្មស្របច្បាប់។

**ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**ក៏បានបង្ហាញពីការត្រៀមខ្លួនជាស្រេចរបស់កម្ពុជា ក្នុងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយគ្រប់ប្រទេស និងអ្នកពាក់ព័ន្ធទូទាំងពិភពលោក ដើម្បីការពារ ប្រទេសរបស់យើងរៀងៗខ្លួន ការពារសហគមន៍សកលពីផលប៉ះពាល់ដ៏គ្រោះថ្នាក់នៃគ្រឿងញៀន សំយោគ និងធានាសុខុមាលភាពរបស់ប្រជាជន៕